00356564

**Declassified to Public**
**06 September 2012**

E22/4

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 31 / JUL / 2009
ម៉ោង (Time/Heure): 09 : 20
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de première instance

សំណុំរឿងលេខ: ០០១/១៨ កក្កដា ២០០៧-អវតក/អជសដ
**Case File/Dossier No. 001/18-07-2007-ECCC/TC**

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 31 / 07 / 2009
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Ratanak

ចំពោះមុខ: ចៅក្រម និល ណុន ជាប្រធាន
ចៅក្រម Silvia CARTWRIGHT
ចៅក្រម យ៉ា សុខន
ចៅក្រម Jean-Marc LAVERGNE
ចៅក្រម ធូ មណី

កាលបរិច្ឆេទ: ថ្ងៃទី ៣០ ខែកក្កដា ឆ្នាំ២០០៩
ចំណាត់ថ្នាក់ឯកសារ: សម្ងាត់បំផុត

# សេចក្តីសម្រេចទៅលើសំណើរបស់សហមេធាវីការពារក្តីសុំតែងតាំងអ្នកជំនាញ ផ្នែកចិត្តវិទ្យាម្នាក់សម្រាប់ កាំង ហ្គេកអ៊ាវ ហៅ ឌុច

**សហព្រះរាជអាជ្ញា**
ជាលាង
Robert PETIT

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី**
គង់ ពិសី
ហុង គឹមសួន
យុង ផានិត
គឹម ម៉េងឃី
ម៉ុច សុវណ្ណារី
Silke STUDZINSKY
Martine JACQUIN
Philippe CANONNE

ទី ស្រីនណា
Pierre Olivier SUR
Alain WERNER
Brianne McGONIGLE
Annie DELAHAIE
Elizabeth RABESANDRATANA
Karim KHAN

**ជនជាប់ចោទ**
កាំង ហ្គេកអ៊ាវ ហៅ ឌុច

**មេធាវីជនជាប់ចោទ**
ការ សាវុត្ថ
François ROUX
Marie-Paule CANIZARES

TRIAL CHAMBER CHAMBRE DE PREMIÈRE INSTANCE E C C C

00356565



**អង្គជំនុំជម្រះសាលាដំបូង** នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ("អវតក")

**ក្រោយពីបានទទួល** សំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អវតក/អជសង អនុលោមតាម "សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះលើករណី កាំង ហ្កេកអ៊ាវ ហៅ ឌុច" ដែលអង្គបុរេជំនុំជម្រះបានសម្រេច និងប្រកាសនៅថ្ងៃទី ០៥ ខែធ្នូ ឆ្នាំ២០០៨ និងបញ្ចូលសេចក្តីសម្រេចនេះជាភាសាខ្មែរទៅក្នុងសំណុំរឿងនៅថ្ងៃទី ០៩ ខែធ្នូ ឆ្នាំ២០០៨

**ក្រោយពីបានទទួល** "សំណើសុំតែងតាំងអ្នកជំនាញផ្នែកចិត្តវិទ្យាម្នាក់សម្រាប់ កាំង ហ្កេកអ៊ាវ ហៅ ឌុច" ដែលបានដាក់ជូនចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ដោយសម្ងាត់បំផុត ដោយសហមេធាវីការពារក្តីកាលពីថ្ងៃទី១៦ ខែមីនា ឆ្នាំ២០០៩[1]

## ចេញសេចក្តីសម្រេចដូចខាងក្រោម៖

## អង្គហេតុ និង សំអាងហេតុ

### ក. អង្គហេតុ

១. សហមេធាវីការពារក្តីបានស្នើសុំតែងតាំងអ្នកជំនាញផ្នែកចិត្តវិទ្យាម្នាក់ដើម្បីជួយដល់ជនជាប់ចោទក្នុងអំឡុងសវនាការលើអង្គសេចក្តី។ តាមរយៈដីការបស់អង្គជំនុំជម្រះសាលាដំបូង សាស្ត្រាចារ្យ កា ស៊ុនបូណាត ត្រូវបានតែងតាំងឲ្យធ្វើការពិនិត្យ និងតាមដាននូវសកម្មភាពរបស់ជនជាប់ចោទក្នុងពេលសវនាការ ដើម្បីធ្វើការកំណត់ថាអ្វីដែលសហមេធាវីការពារក្តីបានលើកឡើងថាជនជាប់ចោទ "នឹងទទួលរងការឈឺចាប់ផ្លូវចិត្តដ៏ធ្ងន់ធ្ងរដែលអាចបណ្តាលឲ្យមានការប៉ះ

---

[1] "សំណើសុំតែងតាំងអ្នកជំនាញផ្នែកចិត្តវិទ្យាម្នាក់សម្រាប់ កាំង ហ្កេកអ៊ាវ ហៅ ឌុច" ថ្ងៃទី១៦ ខែមីនា ឆ្នាំ២០០៩ (ឯកសារ E22) (ឯកសារសម្ងាត់បំផុត)។

ពាល់បញ្ហាផ្នែកចិត្តសាស្ត្រយ៉ាងខ្លាំងនោះជាការពិត ឬយ៉ាងណា ប្រសិនបើគាត់មិនបានទទួលការគាំពារផ្នែកចិត្តសាស្ត្រទេនោះ" ហើយដែលបញ្ហានេះនឹងធ្វើឱ្យគាត់មិនមានសម្បទាគ្រប់គ្រាន់ក្នុងការចូលរួមការជំនុំជម្រះក្តី[2]។

២. របាយការណ៍ដែលត្រូវបានរៀបចំដោយសាស្ត្រាចារ្យ កា ស៊ុនបូណាត ត្រូវបានដាក់ជូនអង្គជំនុំជម្រះនៅថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០៩ និងត្រូវបានជូនដំណឹងដល់សហមេធាវីការពារក្តី[3]។ ឆ្លើយតបទៅនឹងការស្នើសុំរបស់អង្គជំនុំជម្រះសាលាដំបូងនូវយោបល់ស្តីអំពីរបាយការណ៍ដែលបានផ្ញើជូននោះ សហមេធាវីការពារក្តីបានបញ្ជាក់ថា ខ្លួនរក្សាជំហររបស់ខ្លួនដដែលទាក់ទងទៅនឹងសំណើដើមរបស់ខ្លួន[4]។

## ខ. សំអាងហេតុ

៣. របាយការណ៍វាយតម្លៃផ្នែកវិកលវិទ្យាបានបង្ហាញថាក្នុងខណៈដែលគាត់អាចទទួលរងការប៉ះទង្គិចផ្លូវចិត្តមួយរយៈពេលខ្លីកន្លងមកក្នុងអំឡុងពេលនៃដំណើរការនីតិវិធីជំនុំជម្រះក្តីនោះ ជនជាប់ចោទនាពេល "បច្ចុប្បន្ននេះបានធូរស្បើយឡើងវិញហើយនឹងមានភាពរឹងមាំគ្រប់គ្រាន់អាចចូលរួមក្នុងការជំនុំជម្រះក្តី ដោយមិនចាំបាច់មាននូវជំនួយផ្នែកចិត្តសាស្ត្រណាមួយឡើយ"។

៤. អង្គជំនុំជម្រះបានធ្វើការសង្កេតមើលដោយយកចិត្តទុកដាក់នូវអាការៈរបស់ជនជាប់ចោទនៅក្នុងអំឡុងកិច្ចដំណើរការនីតិវិធីជំនុំជម្រះកន្លងមក ហើយបានយល់ស្របជាមួយនឹងសេចក្តី

---

[2] "ដីកាស្តីអំពីសំណើរបស់សហមេធាវីការពារក្តីសុំឱ្យតែងតាំងអ្នកជំនាញផ្នែកចិត្តវិទ្យាម្នាក់សម្រាប់ជនជាប់ចោទ" ថ្ងៃទី៣០ ខែមីនា ឆ្នាំ២០០៩ (ឯកសារ E22/1) (ឯកសារសម្ងាត់បំផុត)។

[3] "របាយការណ៍វាយតម្លៃផ្នែកវិកលវិទ្យា" ថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០៩ (ឯកសារ E22/2) (ឯកសារសម្ងាត់បំផុត)។

[4] Position de la défence sur les conclusions du rapport d'examen psychiatrique du professeur KA Sunbaunat du 16 Juin 2009 ថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០០៩ (ឯកសារ E22/3/1)។ សូមអានលិខិតដែលបានផ្ញើជូនសហមេធាវីការពារក្តីពីអង្គជំនុំជម្រះសាលាដំបូង : "Requête Sollicitant la Désignation d'un Psychologue" ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០០៩ (ឯកសារ E22/3) (ឯកសារសម្ងាត់បំផុត)។

សន្និដ្ឋាននៅក្នុងរបាយការណ៍ដែលបានដាក់ជូនដោយសាស្ត្រាចារ្យ កា ស៊ុនបូណាត។ ដូច្នេះ អង្គជំនុំជម្រះជឿជាក់ថាមិនចាំបាច់មានការតែងតាំងអ្នកជំនាញផ្នែកចិត្តវិទ្យាដើម្បីជួយដល់ជនជាប់ចោទឡើយក្នុងអំឡុងពេលសវនាការលើអង្គសេចក្តី។

៥. អង្គជំនុំជម្រះក៏បានកត់សំគាល់ដែរថា ប្រសិនបើជនជាប់ចោទអាចតម្រូវឱ្យមានការជួយគាំទ្របែបនេះនៅពេលអនាគត អង្គជំនុំជម្រះនឹងរៀបចំឱ្យបានសមស្របដើម្បីស្វះស្វែងរកការវាយតម្លៃផ្នែកចិត្តសាស្ត្របន្ថែមទៀត។

**ហេតុដូច្នេះសម្រេច÷**

**បដិសេធ** សំណើរបស់សហមេធាវីការពារក្តី។ NWR

ភ្នំពេញ ថ្ងៃទី ៣០ ខែកក្កដា ឆ្នាំ២០០៨

**ប្រធានអង្គជំនុំជម្រះសាលាដំបូង**

**និល ណុន**